**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តសៀមរាប**
**ស្រុកពួក**
**ឃុំខ្នាត**
**លេខ:០០១/១៨ ដ.ក**

# ដីកាឃុំ

ស្តីពី

## ការបង្ការ និងទប់ស្កាត់គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង

- បានឃើញច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ឆ្នាំ២០០១
- បានឃើញអនុក្រឹត្យលេខ២២ អនក/បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចឲ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់
- យោងសៀវភៅឯកសារបច្ចេកទេសស្តីពីការបង្ការនិងទប់ស្កាត់គ្រឿងស្រវឹងសម្រាប់រដ្ឋបាលឃុំ/សង្កាត់របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧
- យោងលទ្ធផលសិក្ខាសាលាស្តីពី "វិធានការរួម ដើម្បីបង្ការនិងទប់ស្កាត់ផលប៉ះពាល់នៃគ្រឿងស្រវឹងនៅក្នុងឃុំខ្នាត" នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨
- យោងអង្គប្រជុំក្រុមប្រឹក្សា**ឃុំខ្នាត** ស្តីពីវិធានការបង្ការ និងទប់ស្កាត់គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង ចុះថ្ងៃទី...០៥...ខែ...តុលា.... ឆ្នាំ២០១៨

ដោយមើលឃើញថាបញ្ហាដែលបង្កឡើងដោយអ្នកប្រើប្រាស់គ្រឿងស្រវឹងបានធ្វើឲ្យមានអំពើហិង្សា ភាពឥតសណ្តាប់ធ្នាប់ អសន្តិសុខ ភាពក្រីក្រ និងប៉ះពាល់ដល់សុខភាពជារួមរបស់ប្រជាពលរដ្ឋក្នុង**ឃុំខ្នាត** ដូច្នេះ **ក្រុមប្រឹក្សាឃុំខ្នាត**

## <u>សម្រេច</u>

ប្រការ១៖ ដីកានេះមានគោលបំណងការពារសិទ្ធិស្ត្រី សិទ្ធិកុមារ និងបង្ការអំពើហិង្សា ព្រមទាំងលើកកម្ពស់សុខមាលភាព និងប្រាក់ចំណូលប្រជាពលរដ្ឋ ក៏ដូចជាការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុង**ឃុំខ្នាត**ទាំងមូល។

ប្រការ២៖ ដីកានេះមានវិសាលភាពអនុវត្តទៅលើ អ្នកប្រើប្រាស់គ្រឿងស្រវឹងដែលបង្កបញ្ហា ឬបង្កការរំខាន ឬបង្កហិង្សានានា ព្រមទាំងការលក់ផលិតផលគ្រឿងស្រវឹងទៅឲ្យជន ឬនៅទីកន្លែងមួយចំនួនក្នុង**ឃុំខ្នាត**ដែលមានចែងក្នុងដីកានេះ។

ប្រការ៣៖ ក្រុមប្រឹក្សាឃុំ មេភូមិគ្រប់ភូមិ ព្រះចៅអធិការវត្ត ព្រះសង្ឃ សហគមន៍ នាយកសាលា និងមណ្ឌលសុខភាព ត្រូវបង្កើនការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់នៃគ្រឿងស្រវឹងទៅដល់ប្រជាពលរដ្ឋទូទាំងឃុំឲ្យបានទូលំទូលាយ។ ក្នុងនោះត្រូវមានការណែនាំអ្នកប្រើប្រាស់គ្រឿងស្រវឹងជាប្រចាំឲ្យពួកគាត់កាត់បន្ថយ និងធ្វើការងារ ក៏ដូចជាលេងកីឡាផ្សេងៗឲ្យបានច្រើន។ ករណីអ្នកស្រវឹងបង្កបញ្ហាត្រូវរាយការណ៍ជូនសមត្ថកិច្ចដើម្បីមានវិធានការតាមផ្លូវច្បាប់។

ប្រការ៤៖ ហាមឪពុកម្តាយគ្រប់រូប ឬអាណាព្យាបាលជំរុញ និងលើកទឹកចិត្តកូនៗអោយប្រើប្រាស់គ្រឿងស្រវឹង។

ប្រការ៥៖ ហាមប្រើអោយកុមារទៅទិញ លក់អោយ និងអោយកុមារអាយុក្រោម១៨ឆ្នាំប្រើប្រាស់គ្រឿងស្រវឹង ។

ប្រការ៦៖ ហាមលក់ និងផឹកគ្រឿងស្រវឹងគ្រប់ប្រភេទនៅក្នុងវត្តអារាម គ្រឹះស្ថានសាសនា សាលារៀន សាលាឃុំ ប៉ុស្តិ៍រដ្ឋបាលឃុំ មណ្ឌលសុខភាព ប៉ុស្តិ៍ប្រជាការពារ និងអាគារសាធារណៈនានា។

ប្រការ៧៖ ហាមលើកផ្ទាំងប៉ាណូផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងគ្រប់ប្រភេទ នៅផ្នែកខាងក្នុង និងក្រៅបរិវេណវត្តអារាម គ្រឹះស្ថានសាសនា សាលារៀន សាលាឃុំ ប៉ុស្តិ៍រដ្ឋបាលឃុំ មណ្ឌលសុខភាព ប៉ុស្តិ៍ប្រជាការពារ និងអាគារសាធារណៈ។ ការលើកផ្ទាំងប៉ាណូផ្សព្វផ្សាយពាណិជ្ជកម្មអាចធ្វើទៅបាន ត្រូវមានចម្ងាយយ៉ាងតិច១០០ម៉ែត្រ ពីទីតាំងដែលបានកំណត់លើកឡើងនេះ។

ប្រការ៨៖ ហាមជនគ្រប់រូបដែលប្រើប្រាស់គ្រឿងស្រវឹង បង្កអោយមានសម្លេងរំខានអ្នកដទៃ ហៅទូរស័ព្ទទៅអ្នកដទៃអោយមកប្រើប្រាស់គ្រឿងស្រវឹងជាមួយខ្លួន និងបង្ខំអោយអ្នកដទៃប្រើប្រាស់គ្រឿងស្រវឹង ចាប់ពីម៉ោង១០ យប់ឡើងទៅ។

ប្រការ៩៖ ហាមប្រើប្រាស់គ្រឿងស្រវឹង ក្នុងពិធីបុណ្យប្រពៃណីផ្សេងៗ និងពិធីបុណ្យសាសនា ដូចបានកំណត់នៅក្នុងប្រការ ៦ នៃដីកានេះ។

ប្រការ១០៖ ហាមយកកំប៉ុងផលិតផលស្រាបៀរគ្រប់ប្រភេទ ដាក់ជាកំប៉ុងជើងធូបនៅតាមរោងបុណ្យ វត្តអារាម និងគេហដ្ឋាន។

ប្រការ១១៖ ជនគ្រប់រូបដែលប្រើប្រាស់គ្រឿងស្រវឹង ដែលផ្ទុកជាតិអាកុលហួសកម្រិត ហើយបើកបរយានយន្តគ្រប់ប្រភេទ នឹងត្រូវអនុវត្តទៅតាមច្បាប់ចរាចរណ៍ផ្លូវគោក ដែលមានជាធរមាន។

ប្រការ១២៖ បុគ្គលដែលស្រវឹងដាក់ស្ដែងនៅលើផ្លូវសាធារណៈ និងញុះញង់អោយអនីតិជនដោយផ្ទាល់ អោយប្រើប្រាស់គ្រឿងស្រវឹង មន្ត្រីនគរបាលនឹងអនុវត្តតាមក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានជាធរមាន ត្រង់មាត្រា២៩៧ និងមាត្រា៣៤៣។

ប្រការ១៣៖ ជនទាំងឡាយណាដែលប្រព្រឹត្តិល្មើសប្រការ៤, ៥, ៦, ៧, ៨, ៩ និងប្រការ១០ ត្រូវធ្វើការណែនាំលើកទី១ដោយផ្ទាល់មាត់ លើកទី២និងលើកទី៣ ជាលាយលក្ខណ៍អក្សរ ។ ក្នុងករណី៣លើកនៅមិនរាងចាល អាជ្ញាធរឃុំ ឬនគបាលប៉ុស្តិ៍រដ្ឋបាលឃុំ ត្រូវពិន័យជាប្រាក់ចាប់ពី ១០,០០០រៀល(មួយម៉ឺនរៀល) ទៅ ៥០,០០០រៀល(ប្រាំម៉ឺនរៀល) និងអនុវត្តតាមផ្លូវច្បាប់។

ប្រការ១៤៖ ថវិកាដែលទទួលបានពីការផាកពិន័យត្រូវដាក់បញ្ចូលជាប្រាក់មូលនិធិសម្រាប់អភិវឌ្ឍន៍ឃុំ និងវគ្គបណ្ដុះបណ្ដាលដល់ប្រជាពលរដ្ឋអោយយល់ដឹងពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង។

ប្រការ១៥៖ ឃុំត្រូវបង្កើតគណៈកម្មការ និងជនបង្គោលតាមភូមិស្ម័គ្រចិត្តសម្រាប់ជួយផ្សព្វផ្សាយ និងតាមដានពីប្រសិទ្ធភាពនៃការអនុវត្តន៍ដីកាឃុំ បន្ទាប់ពីបានអនុម័ត។

ប្រការ១៦៖ ឃុំនឹងត្រូវដាក់បញ្ចូលកម្មវិធីអប់រំផ្សព្វផ្សាយផលប៉ះពាល់ស្ដីការប្រើប្រាស់គ្រឿងស្រវឹង និងការធ្វើសកម្មភាពផ្សព្វផ្សាយពីដីកាឃុំ ទៅក្នុងផែនការអភិវឌ្ឍន៍របស់ឃុំ សម្រាប់ធ្វើសកម្មភាពផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅតាមភូមិនិមួយៗ នៅក្នុងឃុំ។

ប្រការ១៧៖ អាជ្ញាធរមូលដ្ឋាន(មេឃុំ ក្រុមប្រឹក្សាឃុំ មេភូមិ នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ) មណ្ឌលសុខភាព ព្រះសង្ឃ គ្រូបង្រៀន និងសហគមន៍ត្រូវធ្វើការផ្សព្វផ្សាយដីកានេះ ជូនដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានអោយបានទូលំទូលាយ។

ប្រការ១៨៖ ដីកានេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅខ្នាត,ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ២០១៨

មេឃុំ

ឡឹក ឡូន